# អង្គការសាលារៀនទន្សាយ

# របាយការណ៍ប្រចាំឆ្នាំ ២០២៥

**អាសយដ្ឋាន៖** ស្ថិតក្នុងសាលាបឋមសិក្សាទួលគោក វិថី២៨៩ ខណ្ឌទួលគោក រាជធានីភ្នំពេញ
**ទូរស័ព្ទទំនាក់ទំនង៖** (+855) 68 901 971 /17 525 815, **អ៊ីម៉ែល៖** info@rabbitschoolcambodia.net
**គេហទំព័រ៖** www.rabbitschoolcambodia.net

## Content


ពាក្យកាត់.....3

1. **របាយការណ៍ហិរញ្ញវត្ថុ ប្រចាំឆ្នាំ ២០២៥**.....4
2. **របាយការណ៍សវនកម្ម**.....4
3. **សមិទ្ធផលសំខាន់ៗ**.....4
4. **ហានិភ័យ ឱកាស និងយុទ្ធសាស្ត្រ**.....9
5. **ចីរភាព**.....10
6. **សកម្មភាពត្រួតពិនិត្យ និងវាយតម្លៃ**.....10
7. **មេរៀនដែលបានរៀន និងនវានុវត្តន៍**.....10
8. **ករណីសិក្សា**.....11

**ឧបសម្ព័ន្ធ៖ រូបថតសមិទ្ធផល**.....13


RSO

# ពាក្យកាត់

| Acronyms/Abbreviations | Full words |
|---|---|
| MoSVY | Ministry of Social Veteran and Youth Rehabilitation |
| MoEYS | Ministry of Education Youth and Sport |
| PoSVY, | Provincial of Social Veteran and Youth Rehabilitation |
| PoE | Provincial Office of Education |
| DoSVY | District of Social Veteran and Youth Rehabilitation |
| DoE | District Office of Education |
| DTMT | District Training and Monitoring Team |
| SSC | School Support Committee |
| SD | School Director |
| DCWC, | District Council for Woman and Children |
| CCWC, | Commune Council for Woman and Children |
| CWID | Children with Intellectual Disabilities |
| OOSC | Out Of School Children |
| PwDs | Person with Disability |
| YwID | Youth with Intellectual disability |
| NGO | Non-Government Organization |
| RSO | Rabbit School Organization |
| NISE | National Institute for Special Education |
| HI | Human Inclusion |
| PPCIL | Phnom Penh Center for Independent Living - PPCIL |
| NEP | NGO Education Partnership |
| CAMFEBA | Cambodian Federation of Employers and Business Associations (CAMFEBA) |
| NEA | National Employment Agency |
| HHC | Hand of Hope Community |

RSO

## 1. របាយការណ៍ហិរញ្ញវត្ថុ ប្រចាំឆ្នាំ ២០២៥

| លេខរៀង | ចំណាយប្រតិបត្តិការណ៍ | ចំនួនទឹកប្រាក់ជាដុល្លារ |
|---|---|---|
| 1 | ចំណាយលើធនធានមនុស្ស | $136,793.04 |
| 2 | ចំណាយលើការធ្វើដំណើរ | $2,036.19 |
| 3 | ចំណាយលើឧបករណ៍ និងសម្ភារៈផ្គត់ផ្គង់ | $7,118.75 |
| 4 | ចំណាយលើគ្រឿងបរិក្ខារក្នុងស្រុក | $10,972.07 |
| 5 | ចំណាយលើសកម្មភាពគម្រោង | $321,954.60 |
| 6 | ចំណាយផ្សេងៗ | $5,970.97 |
| | **Total** | **$484,845.62** |

## 2. របាយការណ៍សង្ខេប

កម្មវិធីអប់រំរបស់អង្គការសាលារៀនទន្យាយ (RSO) ត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយ រួមមាន ការអភិវឌ្ឍន៍ផ្នែកសង្គម អារម្មណ៍ រាងកាយ បញ្ញា និងសមត្ថភាពគិតរបស់កុមារដែលមានពិការភាពសតិបញ្ញា និងអូទីស្សឹម ដោយមានគោលបំណងជួយពួកគេអាចចូលរួមពេញលេញក្នុងសង្គម។ កុមារត្រូវបានទទួលចូលរៀននៅសាលារៀនទន្យាយ ចាប់ពីអាយុ ៤ ឆ្នាំ និងទទួលការគាំទ្ររហូតដល់អាយុ ២៥ ឆ្នាំ។

នៅក្នុងដំណាក់កាលនីមួយៗនៃកម្មវិធីសាលារៀនទន្យាយ សិស្សត្រូវបានវាយតម្លៃ ផ្តល់ការគាំទ្រ និងអប់រំតាមវិធីសាស្ត្រត្រូវបានរៀបចំឡើងឱ្យសមស្របទៅតាមតម្រូវការផ្ទាល់ខ្លួន។ នៅសាលារៀនទន្យាយ កុមារនីមួយៗត្រូវបានលើកទឹកចិត្តឱ្យមានការរីកចម្រើន និងមានភាពឯករាជ្យកាន់តែច្រើន ដោយគិតគូរពីលក្ខណៈពិសេស និងគោលដៅផ្ទាល់ខ្លួនរបស់ពួកគេជានិច្ច។

កម្មវិធីអប់រំរបស់សាលាទន្យាយ រួមមាន ការចូលរៀនថ្នាក់អប់រំពិសេស ថ្នាក់សមាហរណកម្មនិងបរិយាបន្ន អប់រំមុនការបណ្តុះបណ្តាលវិជ្ជាជីវៈ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងឱកាសការងារ និងការសមាហរណកម្មទៅក្នុងសង្គមនៅអាយុ ២៥ ឆ្នាំ។

សាលារៀនទន្យាយបានរៀបចំរបាយការណ៍ប្រចាំឆ្នាំនេះ សម្រាប់ការអនុវត្តគម្រោងរយៈពេលមួយឆ្នាំ ចាប់ពីថ្ងៃទី ១ ខែមករា ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២៥។ របាយការណ៍នេះ បានរៀបចំឡើងដោយផ្អែកលើលទ្ធផល សមិទ្ធផល និងសកម្មភាព។

## 3. សមិទ្ធផលសំខាន់ៗ

ក្នុងឆ្នាំ ២០២៥ គម្រោងបានសម្រេចវឌ្ឍនភាពសំខាន់ៗដែលអាចវាស់វែងបាន ក្នុងការពង្រីកការអប់រំបរិយាបន្ន និងពង្រឹងសមត្ថភាពប្រព័ន្ធអប់រំ នៅតាមខេត្តគោលដៅ។ កុមារក្រៅសាលា (OOSC) សរុប ៥១៤ នាក់ (ស្រី ២៣៤ នាក់) ត្រូវបានកំណត់អត្តសញ្ញាណថ្មី និងចូលរៀនវិញ ខណៈកុមារ ៥០០ នាក់ (ស្រី ២៤០ នាក់) ទទួលបានអាហារូបករណ៍ជាសម្ភារៈដើម្បីគាំទ្របន្តការសិក្សា។

គម្រោងបានគាំទ្រថ្នាក់សមាហរណកម្មចំនួន ៥៣ ថ្នាក់ នៅសាលាបឋមសិក្សា ១៦ សាលា ដែលផ្តល់អត្ថប្រយោជន៍ដល់សិស្សពិការចំនួន ៥៣៧ នាក់ (ស្រី ១២៧ នាក់) និងបានបំពាក់ថ្នាក់រៀនអប់រំរួមចំនួន ៧០ ថ្នាក់ នៅខេត្តកំពង់ស្ពឺ កណ្តាល និងសៀមរាប ដែលបានចូលរួមគាំទ្រតាមដានជាប្រព័ន្ធដល់កុមារក្រៅសាលាចំនួន ២,១៤៤ នាក់។

ក្នុងភាពជាដៃគូជាមួយវិទ្យាស្ថានជាតិអប់រំពិសេស (NISE) សិស្សពិការចំនួន ២៦១ នាក់ (ស្រី ១០២ នាក់) ត្រូវបានកំណត់អត្តសញ្ញាណថ្មី និងចូលរៀន។ ដើម្បីធានាគុណភាព និងចីរភាព គ្រូអប់រំពិសេសចំនួន ៦៤ នាក់ (ស្រី ៤៨ នាក់) ទទួលបាន

ការអភិវឌ្ឍវិជ្ជាជីវៈបន្ត។ ឪពុកម្តាយចំនួន ៤២ នាក់ (ស្រី ៣២ នាក់) ត្រូវបានបណ្តុះបណ្តាល ដើម្បីពង្រឹងកិច្ចសហការសហគមន៍និងសាលា និងលើកកម្ពស់ផ្លូវឆ្ពោះទៅកាន់ឱកាសបន្តការសិក្សា និងការងារនាពេលអនាគត។

## លទ្ធផលទី ១៖ ការអប់រំសមស្របសម្រាប់កុមារក្រៅសាលា នៅខេត្ត ៥ (ភ្នំពេញ កណ្តាល កំពង់ស្ពឺ សៀមរាប និងបាត់ដំបង)

ក្នុងឆ្នាំសិក្សា ២០២៤–២០២៥ កុមារក្រៅសាលា ចំនួនសរុប ៥១៤ នាក់ (ស្រី ២៣៤ នាក់) ត្រូវបានកំណត់អត្តសញ្ញាណថ្មី និងចុះឈ្មោះចូលរៀនវិញ។ ក្នុងនោះ កុមារ ៥០០ នាក់ (ស្រី ២៤០ នាក់) ទទួលបានអាហារូបករណ៍ជាសម្ភារៈសិក្សា រួមមាន កុមារ ១៦០ នាក់ (ស្រី ៨៤ នាក់) ពីខេត្តកំពង់ស្ពឺ ២០៤ នាក់ (ស្រី ១០៧ នាក់) ពីខេត្តកណ្តាល និង ១៣៦ នាក់ (ស្រី ៤៩ នាក់) ពីខេត្តសៀមរាប។

ថ្នាក់សមាហរណកម្មចំនួន ៥៣ ថ្នាក់ នៅសាលាបឋមសិក្សាគោលដៅ ១៦ សាលា រួមទាំងថ្នាក់ថ្មីចំនួន ៥ នៅសាលាបឋមសិក្សាទួលគោក ដែលបម្រើសិស្សពិការចំនួន ៥៣៧ នាក់ (ស្រី ១២៧ នាក់) បានទទួលសម្ភារៈបង្រៀន និងសម្ភារៈសម្អាតពីអង្គការសាលារៀនទន្សាយ។ បន្ថែមពីនេះ ថ្នាក់អប់រំបរិយាបន្នចំនួន ៧០ ថ្នាក់ នៅសាលាបឋមសិក្សាគោលដៅ ៧០ សាលា (២៥ សាលា នៅកំពង់ស្ពឺ ២៥ សាលា នៅកណ្តាល និង ២០ សាលា នៅសៀមរាប) ត្រូវបានសម្ភារៈបង្រៀន ដែលបានចូលរួមគាំទ្រការតាមដានជាប្រព័ន្ធដល់កុមារក្រៅសាលាចំនួន ២,១៤៤ នាក់។

ក្នុងភាពជាដៃគូជាមួយវិទ្យាស្ថានជាតិអប់រំពិសេស សិស្សពិការចំនួន ២៦១ នាក់ (ស្រី ១០២ នាក់) ត្រូវបានកំណត់អត្តសញ្ញាណ និងចុះឈ្មោះចូលរៀន រួមមាន សិស្សពិការភ្នែក ៥២ នាក់ (ស្រី ២១ នាក់) សិស្សពិការស្តាប់ ១៦៩ នាក់ (ស្រី ៨៣ នាក់) និងសិស្សពិការសតិបញ្ញា និងអូទីស្សឹម ៤៥ នាក់ (ស្រី ៦ នាក់)។ សិស្សទាំងអស់ទទួលបានអាហារូបករណ៍ រួមមាន ឯកសណ្ឋានសិស្ស សម្ភារៈសិក្សា និងកាបូបស្ពាយ។ ឧបករណ៍ជំនួយត្រូវបានផ្តល់ជូនតាមតម្រូវការ រួមមាន ឈើច្រត់ពណ៌ស ១៣ ដើម និងវ៉ែនតា ១៧ គូ។

បន្ថែមពីនេះ វិទ្យាស្ថានជាតិអប់រំពិសេស បានគាំទ្រវិទ្យាល័យអប់រំពិសេសចំនួន ៣ ដោយធ្វើការកែលម្អថ្នាក់ពិសេសចំនួន ៥ ថ្នាក់ (៣ ថ្នាក់ នៅបាត់ដំបង ១ ថ្នាក់ នៅសៀមរាប និង ១ ថ្នាក់ នៅច្បារអំពៅ រាជធានីភ្នំពេញ)។ ថ្នាក់រៀនទាំងនេះត្រូវបានជួសជុល និងបំពាក់គ្រឿងសង្ហារឹម និងសម្ភារៈសិក្សាចាំបាច់ រួមមាន ក្តារខៀន តុ ធ្នើ សន្លឹកកាតអប់រំ សៀវភៅ បដា និងឧបករណ៍បង្រៀនផ្សេងៗ។ វិទ្យាស្ថានជាតិអប់រំពិសេស ក៏បានជួសជុលបង្គន់ជនមានពិការភាព ចំនួន ២ កន្លែង នៅសៀមរាប និងច្បារអំពៅ ដោយបន្ថែមជម្រាល និងបង្កាន់ដៃ ដើម្បីបង្កើនសុវត្ថិភាព និងភាពងាយស្រួលក្នុងការប្រើប្រាស់។

## លទ្ធផលទី ២៖ ការកសាងសមត្ថភាពគ្រូបង្រៀន

ក្នុងខែមិថុនា ឆ្នាំ ២០២៥ សិក្ខាសាលាបណ្តុះបណ្តាលស្តីអំពីអប់រំពិសេសចំនួន ៣ ត្រូវបានរៀបចំឡើង ដោយមានអ្នកចូលរួមសរុប ៨៤ នាក់ (ស្រី ៦៦ នាក់) រួមមានគ្រូអប់រំពិសេស និងអ្នកដឹកនាំបច្ចេកទេស ពីភ្នំពេញ កណ្តាល កំពង់ស្ពឺ និងសៀមរាប។ សិក្ខាសាលាត្រូវបានរៀបចំថ្ងៃទី ១២ មិថុនា នៅកំពង់ស្ពឺ (៣៦ នាក់) ថ្ងៃទី ១៩ មិថុនា នៅសៀមរាប (២១ នាក់) និងថ្ងៃទី ២៣ មិថុនា នៅវិទ្យាស្ថានជាតិអប់រំពិសេស (NISE) ភ្នំពេញ (២៧ នាក់)។ គោលបំណងគឺពង្រឹងសមត្ថភាពគ្រូ និងបុគ្គលិកបច្ចេកទេស ក្នុងការផ្តល់ការអប់រំដែលមានគុណភាពសម្រាប់កុមារពិការ។

ក្នុងខែមិថុនា ឆ្នាំ ២០២៥ ផងដែរ សិក្ខាសាលាបណ្តុះបណ្តាលស្តីអំពីអប់រំបរិយាបន្នចំនួន ២ ត្រូវបានរៀបចំ ដោយមានអ្នកចូលរួម ៧៥ នាក់ (ស្រី ៥៤ នាក់) រួមមានគ្រូអប់រំបរិយាបន្ន និងគ្រូបច្ចេកទេស ពីកណ្តាល កំពង់ស្ពឺ និងសៀមរាប។ សិក្ខាសាលាបានរៀបចំថ្ងៃទី ១៣ មិថុនា នៅកំពង់ស្ពឺ (៥៣ នាក់) និងថ្ងៃទី ២០ មិថុនា នៅសៀមរាប (២២ នាក់) ដើម្បីពង្រឹងសមត្ថភាពគ្រូ ក្នុងការអនុវត្តអប់រំបរិយាបន្ន និងលើកកម្ពស់ការអប់រំដោយស្មើភាព ជាពិសេសសម្រាប់កុមារមានពិការភាព។

កិច្ចប្រជុំបច្ចេកទេសសរុប ៣៦ លើក ត្រូវបានអនុវត្ត ដោយមានអ្នកចូលរួម ៦០ នាក់ (ស្រី ៥០ នាក់) រួមមានគ្រូអប់រំពិសេស និងបុគ្គលិកបច្ចេកទេស នៅខេត្តគោលដៅ ៤ គឺ កំពង់ស្ពឺ កណ្តាល ភ្នំពេញ និងសៀមរាប។ ប្រធានបទផ្តោតលើការគ្រប់គ្រងថ្នាក់រៀន និងរដ្ឋបាល ការរៀបចំ និងអនុវត្តផែនការអប់រំផ្ទាល់ខ្លួន (IEP) ការវាយតម្លៃសិស្ស ការរៀបចំផែនការមេរៀន យុទ្ធសាស្ត្រទំនាក់ទំនង និងការអភិវឌ្ឍសម្ភារៈបង្រៀន។

គ្រូអប់រំពិសេសចំនួន ៦៤ នាក់ (ស្រី ៤៨ នាក់) ត្រូវបានចុះកិច្ចសន្យាការងារ និងបន្តការងារជាគ្រូអប់រំពិសេស ដោយទទួលបានការគាំទ្រការកសាងសមត្ថភាពជាបន្តបន្ទាប់ នៅសាលាបឋមសិក្សាគោលដៅ ១៦ សាលា ក្នុងភ្នំពេញ កណ្តាល កំពង់ស្ពឺ និងសៀមរាប។ បន្ថែមពីនេះ វិទ្យាស្ថានជាតិអប់រំពិសេស បានផ្តល់ប្រាក់លើកទឹកចិត្តដល់គ្រូ ១០ នាក់ (ស្រី ៧ នាក់) រួមមានគ្រូអប់រំពិសេសថ្មី ៥ នាក់ ដែលត្រូវបានចាត់តាំងឱ្យគាំទ្រសិស្សពិការសតិបញ្ញា និងអូទីស្សឹម នៅវិទ្យាល័យអប់រំពិសេស ៣ កន្លែង ក្នុងបាត់ដំបង សៀមរាប និងភ្នំពេញ។

គ្រូបង្រៀនការនិយាយចំនួន ១១ នាក់ (ស្រី ៨ នាក់) បានបញ្ចប់កម្មវិធីបណ្តុះបណ្តាលព្យាបាលការនិយាយ ដឹកនាំដោយគ្រូឧទ្ទេសបរទេស Judykaël Nicollet នៅខែកញ្ញា ឆ្នាំ ២០២៥។ ការបណ្តុះបណ្តាលផ្តោតលើការវាយតម្លៃតម្រូវការប្រាស្រ័យទាក់ទង និងយុទ្ធសាស្ត្រគាំទ្រសម្រាប់កុមារពិការសតិបញ្ញា និងអូទីស្សឹម។ ចាប់ពីខែតុលា ឆ្នាំ ២០២៥ សាលារៀនទន្សាយ បានសហការជាមួយអង្គការ DSI ដើម្បីអភិវឌ្ឍឧបករណ៍វាយតម្លៃសិស្សដែលត្រូវការគាំទ្រផ្នែកការនិយាយ និងប្រាស្រ័យទាក់ទង។ DSI ក៏បានផ្តល់ប្រឹក្សាបច្ចេកទេស និងការបណ្តុះបណ្តាលជាបន្ត ដើម្បីធានាការអនុវត្តកម្មវិធីថ្មីមានប្រសិទ្ធភាព។

ថ្ងៃទី ២៨ តុលា ឆ្នាំ ២០២៥ សាលារៀនទន្សាយ បានរៀបចំវគ្គបណ្តុះបណ្តាលអំពីការគ្រប់គ្រងស្ត្រេស និងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព សម្រាប់គ្រូអប់រំពិសេស ១៧ នាក់ (ស្រី ១៦ នាក់)។ គោលបំណងគឺលើកកម្ពស់សុខុមាលភាពគ្រូ និងពង្រឹងទំនាក់ទំនងវិជ្ជាជីវៈ។ អ្នកចូលរួមបានសិក្សាអំពីមូលហេតុស្ត្រេសសំខាន់ៗ និងបច្ចេកទេសអនុវត្តដូចជា វិធីបន្ធូរអារម្មណ៍ ការគ្រប់គ្រងពេលវេលា យុទ្ធសាស្ត្រដោះស្រាយបញ្ហា និងជំនាញទំនាក់ទំនងមានប្រសិទ្ធភាព។

ចន្លោះខែកញ្ញា ដល់ខែធ្នូ ឆ្នាំ ២០២៥ វិទ្យាស្ថានជាតិអប់រំពិសេស បានពង្រឹងសមត្ថភាពអ្នកពាក់ព័ន្ធអប់រំពិសេស តាមរយៈការបណ្តុះបណ្តាល និងបណ្តុះបណ្តាលបន្តបច្ចេកទេស។ សិក្ខាសាលាចំនួន ៣ ត្រូវបានរៀបចំ នៅសៀមរាប បាត់ដំបង និងភ្នំពេញ សម្រាប់អ្នកចូលរួម ២៤ នាក់ (ស្រី ១៤ នាក់) រួមមាន គ្រូអប់រំពិសេស មន្ត្រីការិយាល័យអប់រំខេត្ត និងបុគ្គលិកវិទ្យាស្ថានជាតិអប់រំពិសេស។ ប្រធានបទ រួមមាន ការអភិវឌ្ឍកុមារ (អាយុ ៦–១២ ឆ្នាំ) ការកំណត់អត្តសញ្ញាណ និងបញ្ជូនកុមារពិការ ការគាំទ្រកុមារពិការសតិបញ្ញា និងអូទីស្សឹម បញ្ហាការនិយាយ និងភាសា ការគ្រប់គ្រងអាកប្បកិរិយា ការរៀបចំ IEP អនុវត្តអប់រំរួម និងយុទ្ធសាស្ត្របង្រៀនជាក់ស្តែង។

បន្ថែមពីនេះ ការតាមដាន និងបណ្តុះបណ្តាលបន្តបច្ចេកទេសចំនួន ៦ លើក (២ លើកក្នុងមួយខេត្ត) ត្រូវបានអនុវត្ត ដោយមានអ្នកចូលរួម ២៣ នាក់ (ស្រី ១៣ នាក់) រួមមានគ្រូ នាយកសាលា និងបុគ្គលិកវិទ្យាស្ថានជាតិអប់រំពិសេស។ ប្រធានបទផ្តោតលើការបណ្តុះបណ្តាលនៅថ្នាក់រៀន ការវាយតម្លៃសិស្ស និងរៀបចំផែនការបង្រៀនផ្ទាល់ខ្លួន (ITP) ការតាមដានគម្រោង ការត្រួតពិនិត្យសម្ភារៈ ការគ្រប់គ្រងថ្នាក់រៀន ការចូលរួមរបស់ឪពុកម្តាយ និងការពង្រឹងការគ្រប់គ្រងរដ្ឋបាល។

ថ្ងៃទី ១ សីហា ឆ្នាំ ២០២៥ ក្រុមការងារវិទ្យាស្ថានជាតិអប់រំពិសេស បានចុះទស្សនកិច្ចទៅសាលាបឋមសិក្សាកំពង់ចាស់ ខេត្តព្រះសីហនុ ដើម្បីណែនាំគម្រោងរួមថ្មីជាមួយអង្គការ Aide et Action។ កិច្ចប្រជុំមានអ្នកចូលរួម ១១ នាក់ (ស្រី ៦ នាក់) ក្រោមអធិបតីភាព លោកជំទាវ នាង ផល្លា ហើយបានកំណត់តម្រូវការគាំទ្រសំខាន់ៗ រួមមានការជ្រើសរើសគ្រូអប់រំពិសេស និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ។ ជាលទ្ធផល គ្រូអប់រំពិសេស ២ នាក់ ត្រូវបានជ្រើសរើស និងថ្នាក់រៀន ២ បង្គន់ ១ និងទីលានលេង ១ ត្រូវបានជ្រើសរើសសម្រាប់ការជួសជុល។

## លទ្ធផលទី ៣៖ សាធារណជន និងអាជ្ញាធរមូលដ្ឋាន យល់ដឹង និងគាំទ្រការអប់រំកុមារមានពិការភាព

ថ្ងៃទី ៦–៧ ខែកុម្ភៈ ឆ្នាំ ២០២៥ ក្រុមគ្រប់គ្រងជាន់ខ្ពស់របស់សាលារៀនទន្សាយ (RSO) បានចុះទស្សនកិច្ច ដើម្បីពង្រឹងទំនាក់ទំនងជាមួយសាលាដៃគូ និងវាយតម្លៃតម្រូវការថ្នាក់សមាហរណកម្មទាំងអស់ នៅស្រុកពួក ខេត្តសៀមរាប។ ក្រុមការងាររួមមាន លោកស្រី សរ សុធារម្យ (នាយិកាប្រតិបត្តិ) លោក លឹម សុភាន់ (ប្រធានកម្មវិធី) លោកស្រី អ៊ួង ប៊ុនសូដានី (ប្រធានហិរញ្ញវត្ថុ) កញ្ញា Ines Carles (អ្នកគ្រប់គ្រងទំនាក់ទំនង) និងលោក ញឹប ធី (មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ)។

ថ្ងៃទី ២៤ មេសា ឆ្នាំ ២០២៥ ដោយមានការគាំទ្រពីលោក Yuki Kanayama ម៉ូតូកង់បីចំនួន ២ គ្រឿង ត្រូវបានប្រគល់ជូនសាលាបឋមសិក្សាយាង និងសាលាបឋមសិក្សាអធិបតី ដើម្បីជួយសម្រួលការដឹកជញ្ជូនសិស្សមានពិការភាព និងកាត់បន្ថយបញ្ហាប្រឈមការរៀនសូត្រ។ ក្នុងឱកាសនោះ លោក Yuki បានសម្ភាសឪពុកម្តាយ ១០ នាក់ ដើម្បីយល់ដឹងពីបទពិសោធន៍ និងផលប៉ះពាល់នៃការគាំទ្រដឹកជញ្ជូនលើការសិក្សារបស់កូនៗ។ បន្តពីកិច្ចសហការនេះ នៅខែសីហា ឆ្នាំ ២០២៥ សាលារៀនទន្សាយ បានសហការជាមួយ Yuki Kanayama ដើម្បីសិក្សាស្ទង់មតិអ្នកថែទាំ និងគ្រូបង្រៀន នៅសាលាគោលដៅ ដើម្បីវាយតម្លៃស្ថានភាពអប់រំបរិយាបន្ន និងតម្រូវការ។ លទ្ធផលស្ទង់មតិអ្នកថែទាំ (២៣២ នាក់ នៅ ៤ ខេត្ត) បង្ហាញពីកម្រិតភាពក្រីក្រ ខ្វះសន្តិសុខស្បៀង (ជាពិសេសនៅសៀមរាប) បន្ទុកថែទាំធ្ងន់ធ្ងរ តម្រូវការថែទាំសុខភាពមិនទាន់បំពេញ និងការទទួលបានការការពារសង្គមមានកម្រិត រួមទាំងប័ណ្ណសម្គាល់ពិការភាព។ ស្ទង់មតិគ្រូ (២៥ នាក់ នៅ ៣ ខេត្ត) បង្ហាញបញ្ហាក្នុងការគ្រប់គ្រងអាកប្បកិរិយា កង្វះសម្ភារៈ និងឧបករណ៍បង្រៀន និងការលំបាកក្នុងការវាយតម្លៃ និងទំនាក់ទំនងអំពីវឌ្ឍនភាពសិស្ស។ លទ្ធផលទាំងនេះបញ្ជាក់ពីតម្រូវការពង្រឹងប្រព័ន្ធគាំទ្រគ្រួសារ ពង្រីកការចូលដំណើរការការការពារសង្គម ពង្រឹងសមត្ថភាព និងធនធានគ្រូ និងពង្រឹងប្រព័ន្ធទិន្នន័យសម្រាប់កម្មវិធីអប់រំបរិយាបន្នផ្អែកលើកស្តុតាង។

ថ្ងៃទី ១ មិថុនា ឆ្នាំ ២០២៥ សាលារៀនទន្សាយ បានចូលរួមអបអរសាទរទិវាកុមារអន្តរជាតិ ដោយរៀបចំព្រឹត្តិការណ៍ "Run by Heart" នៅពហុកីឡដ្ឋានជាតិអូឡាំពិក ដោយមានការគាំទ្រពីក្រុមហ៊ុន Dai-ichi Life Insurance Cambodia។ ព្រឹត្តិការណ៍នេះបានប្រមូលផ្តុំអ្នកចូលរួមរាប់រយនាក់ បង្ហាញសាមគ្គីភាព និងគាំទ្រកុមារអូទីស្សឹម និងពិការសតិបញ្ញា។ ព្រឹត្តិការណ៍ត្រូវបានអញ្ជើញចូលរួមដោយភ្ញៀវកិត្តិយសជាច្រើន រួមមាន ឯកឧត្តម សំហេង បុរស ឯកឧត្តម សុខ សាបាយណា តំណាងសហភាពសហព័ន្ធយុវជនកម្ពុជា លោក Mah Kinyoong អគ្គនាយកក្រុមហ៊ុន Dai-ichi Life ឯកឧត្តម Derek Yip ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំកម្ពុជា ឯកឧត្តមបណ្ឌិត Santo Darmosumarto ឯកអគ្គរដ្ឋទូតឥណ្ឌូណេស៊ីប្រចាំកម្ពុជា លោកស្រី អ៊ឹម រចនា ប្រធាន SSEAYP International Cambodia ព្រមទាំងដៃគូអភិវឌ្ឍន៍ និងតំណាងក្រុមហ៊ុនជាច្រើន។

ថ្ងៃទី ៦ មិថុនា ឆ្នាំ ២០២៥ ក្រុមការងារសាលារៀនទន្សាយ បានទទួលដំណើរទស្សនកិច្ច ដឹកនាំដោយអង្គការ AEA នៅស្រុកពួក ខេត្តសៀមរាប។ អ្នកចូលរួមសរុប ១០ នាក់ (ស្រី ៣ នាក់) រួមមានបុគ្គលិក AEA ៥ នាក់ គ្រូអប់រំពិសេស ២ នាក់ នាយកសាលា ១ នាក់ និងក្រុមសាលារៀនទន្សាយ ២ នាក់។ ក្រុមការងារបានសង្កេតមើលថ្នាក់អប់រំពិសេសមួយ ដែលមានសិស្សពិការសតិបញ្ញា និងអូទីស្សឹម ៤ នាក់។

ថ្ងៃដូចគ្នា Manulife បានផ្តល់វេទិកាគាំទ្រសម្រាប់ឪពុកម្តាយកុមារ និងយុវជនពិការសតិបញ្ញា និងអូទីស្សឹម ដោយផ្តល់យុទ្ធសាស្ត្រអនុវត្តសម្រាប់គាំទ្រការអភិវឌ្ឍការនិយាយនៅតាមផ្ទះ និងការគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារ។ ការជួបជុំក៏បានបង្កើតបណ្តាញគាំទ្ររវាងគ្រួសារ កាត់បន្ថយភាពឯកា និងពង្រឹងសហគមន៍។

ថ្ងៃទី ២៧ មិថុនា ឆ្នាំ ២០២៥ ក្រុមការងារ EAC បានមកទស្សនកិច្ចសាលារៀនទន្សាយ ដើម្បីពិនិត្យវឌ្ឍនភាពប្រព័ន្ធតាមដាន និងវាយតម្លៃទិន្នន័យរបស់គម្រោង CCOSC ដែលដឹកនាំដោយ AEA សហការជាមួយកម្មវិធី Educate A Child នៃ Education Above All។ ការទស្សនកិច្ចផ្តោតលើការពិនិត្យដំណើរការប្រមូលទិន្នន័យ និងវាយតម្លៃផលប៉ះពាល់ក្នុងការចូលដំណើរការអប់រំសម្រាប់កុមារក្នុងស្ថានភាពងាយរងគ្រោះ។

បុគ្គលិកគ្រប់គ្រង និងបច្ចេកទេស ៥ នាក់ (ស្រី ២ នាក់) បានចូលរួមវេទិកាជាតិលើកទី ១៣ ស្តីពីអប់រំបរិយាបន្ន នៅថ្ងៃទី ១៥ ធ្នូ ឆ្នាំ ២០២៥ ខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាព ឯកឧត្តម ណុះ ស្លេះ រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា។

RSO

មានអ្នកចូលរួមសរុប ២៤០ នាក់ (ស្រី ៩៧ នាក់)។ ក្នុងឱកាសនេះ សាលារៀនទន្សាយ និងសាលាគោលដៅ ១៦ សាលា ទទួលបានលិខិតសរសើរពីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់ការអប់រំបរិយាបន្ន និងសមាហរណកម្ម។

ក្នុងឆ្នាំ ២០២៥ សាលារៀនទន្សាយ ក៏បានចូលរួមសកម្មភាពតស៊ូមតិ និងបណ្តាញជាច្រើន ដូចជា៖

- ថ្ងៃទី ១០ កញ្ញា ចូលរួមអបអរសាទរទិវាអក្ខរកម្មអន្តរជាតិ និងជាតិ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអំពីអប់រំបរិយាបន្នក្នុងយុគសម័យឌីជីថល។
- ថ្ងៃទី ៣០ តុលា ចូលរួមពិធីបើកដាក់ឱ្យប្រើប្រាស់បន្ទប់កុំព្យូទ័រ នៅសាលាបឋមសិក្សាខ្នាត ស្រុកពួក ខេត្តសៀមរាប និងទស្សនកិច្ចសាលារួមគ្នា។
- ថ្ងៃទី ៣ ធ្នូ ចូលរួមទិវាជនពិការកម្ពុជាលើកទី ២៧ និងទិវាជនពិការអន្តរជាតិលើកទី ៤៣ នៅសាលប្រជុំកោះពេជ្រ ក្រោមអធិបតីភាព ឯកឧត្តមសន្តិបណ្ឌិត នេត សារឿន ដើម្បីបន្តលើកកម្ពស់បរិយាកាសបរិយាបន្នសម្រាប់ជនមានពិការភាព និងធានាអប់រំមានគុណភាព និងស្មើភាពសម្រាប់កុមារពិការសតិបញ្ញា និងអូទីស្សឹម។

## លទ្ធផលទី ៤៖ ពង្រឹងសមត្ថភាពឪពុកម្តាយ តាមរយៈការបណ្តុះបណ្តាល និងក្រុមប្រឹក្សាយោបល់

ក្នុងឆ្នាំ ២០២៥ អង្គការសាលារៀនទន្សាយ បានពង្រឹងការចូលរួមរបស់ឪពុកម្តាយ តាមរយៈសកម្មភាពកសាងសមត្ថភាព និងទស្សនកិច្ចសិក្សាជាបន្តបន្ទាប់។ ឪពុកម្តាយសរុប ៤២ នាក់ (ស្រី ៣២ នាក់) ទទួលបានការបណ្តុះបណ្តាលអំពីការយល់ដឹងអំពីពិការភាព អប់រំពិសេស សុខភាពផ្លូវចិត្ត ការរួមបញ្ចូលវប្បធម៌ និងយុទ្ធសាស្ត្រអនុវត្តសម្រាប់គាំទ្រកុមារអូទីស្សឹម និងពិការសតិបញ្ញា រួមទាំងជំនាញប្រាស្រ័យទាក់ទង និងផ្លូវឆ្ពោះទៅកាន់ការងារសមស្រប និងអាជីព។ ថ្ងៃទី ២៥ មិថុនា ឆ្នាំ ២០២៥ ឪពុកម្តាយ ១១ នាក់ (ស្រី ១០ នាក់) បានចូលរួមទស្សនកិច្ចអាជីវកម្មឯកជនដែលមានលក្ខណៈបរិយាបន្ន នៅខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយបានសង្កេតឃើញយុវជនពិការសតិបញ្ញាកំពុងធ្វើការនៅហាងកាហ្វេ ហាងលក់ទំនិញ សេវាកម្មអាហារ និងហាងលក់សម្លៀកបំពាក់។ សកម្មភាពនេះបានលើកទឹកចិត្តឪពុកម្តាយឱ្យគាំទ្រកូនៗក្នុងការងារ ការបណ្តុះបណ្តាលបម្រើការងារ និងការចូលរួមក្នុងអាជីវកម្មគ្រួសារ។

ថ្ងៃទី ២០ សីហា ឆ្នាំ ២០២៥ សាលារៀនទន្សាយ បានរៀបចំវគ្គបណ្តុះបណ្តាលបន្ថែមចំនួន ៣ សម្រាប់ឪពុកម្តាយ ៥៩ នាក់ (ស្រី ៤៦ នាក់) នៅភ្នំពេញ កណ្តាល និងកំពង់ស្ពឺ ដោយផ្តោតលើឱកាសការងារសមស្រប ផ្លូវព្យាបាល និងការរួមបញ្ចូលសង្គមសម្រាប់មនុស្សពេញវ័យពិការសតិបញ្ញា។ បន្ទាប់មក នៅថ្ងៃទី ២៨ វិច្ឆិកា ឆ្នាំ ២០២៥ ឪពុកម្តាយដែលបានបណ្តុះបណ្តាលចំនួន ២១ នាក់ (ស្រី ១២ នាក់) បានបង្កើតក្រុមគាំទ្រឪពុកម្តាយ ដោយប្តេជ្ញាចូលរួមការតស៊ូមតិសហគមន៍ ដើម្បីលើកកម្ពស់ការយល់ដឹង ការទទួលយក និងការរួមបញ្ចូលកុមារពិការសតិបញ្ញាក្នុងសង្គមកម្ពុជា។

ចន្លោះពីខែមករា ដល់ខែធ្នូ ឆ្នាំ ២០២៥ បណ្តាញសង្គមរបស់យើងបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការលើកកម្ពស់ការយល់ដឹង និងភ្ជាប់ទំនាក់ទំនងជាមួយឪពុកម្តាយ និងអ្នកថែទាំ។

- ទំព័រហ្វេសប៊ុក Facebook របស់យើងកើនដល់ ៤,៩៩២ អ្នកតាមដាន (+១៦.៧%) ដោយទទួលបានអ្នកតាមដានថ្មី ៦៦៨ នាក់ ហើយ ៩៦.៩% នៃការកើនឡើងនេះកើតឡើងដោយសារការចូលរួមធម្មជាតិ (organic reach)។ ទស្សនិកជនភាគច្រើនស្ថិតនៅកម្ពុជា (៩៤%) និងមានការឈានដល់អន្តរជាតិតិចតួច (១.៦% ពីសហរដ្ឋអាមេរិក)។ ការចូលរួមកើនឡើងយ៉ាងខ្លាំងដល់ ១១,១៣២ ប្រតិកម្ម (+១៤៩.១%) រួមមាន ៩,០០១ ប្រតិកម្ម (reactions) ១,០២២ មតិយោបល់ និង ១,១០៩ ការចែករំលែក បង្ហាញពីសហគមន៍ដែលសកម្ម និងមានភាពស្មោះត្រង់។ សរុបមកទិន្នន័យទទួលបាន ៤១៤,៣១៦ ការមើល ប្រហែល ៦០% មកពីអ្នកមិនទាន់តាមដាន ដែលបានពង្រីកឥទ្ធិពលនៃការតស៊ូមតិរបស់យើងឲ្យលើសពីទស្សនិកជនបច្ចុប្បន្ន។

- គណនី Instagram ទទួលបានការមើលសរុប ១៩.៤K ដោយមានប្រសិទ្ធភាពខ្ពស់បំផុតក្នុងខែតុលា និងវិច្ឆិកា អំឡុងយុទ្ធនាការបុណ្យណូអែល។ ការឈានដល់សរុប ២.៥K កើនឡើង ៤,៧០០% ប្រៀបធៀបនឹងរយៈពេលមុន។ ការចូលរួមមាតិកាសរុប ២៨៦ (១០០% ជាការចូលរួមធម្មជាតិ) ខណៈការចូលទស្សនាប្រូហ្វាលកើនដល់ ៦២៣ (+៣៤៨.២%)។ គណនីទទួលបានអ្នកតាមដានថ្មី ៥១ នាក់។ ទិន្នន័យទាំងនេះបង្ហាញពីសន្ទុះកើនឡើងខ្លាំងនៅត្រីមាសចុងឆ្នាំ បង្ហាញពីភាពមើលឃើញមាតិកា និងការចាប់អារម្មណ៍កើនឡើងពីទស្សនិកជន។

ដើម្បីស្វែងយល់បន្ថែមអំពីយើង សូមចូលទស្សនាបណ្តាញសង្គមរបស់យើង៖

🌐 គេហទំព័រ៖ rabbitschoolcambodia.net

📘 ហ្វេសប៊ុក៖ fb.com/rabbitschoolcbd

📸 Instagram៖ instagram.com/rabbitschoolcbd

## 4. ហានិភ័យ ឱកាស និងយុទ្ធសាស្ត្រ

### ហានិភ័យ និងឱកាស

បញ្ហាប្រឈមជាច្រើននៅតែបន្តរារាំងការអភិវឌ្ឍអប់រំបរិយាបន្ន និងការបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់កុមារ និងយុវជនពិការ សតិបញ្ញា និងអូទីស្សឹម នៅកម្ពុជា។ បញ្ហាទាំងនេះរួមមាន៖

- ការគាំទ្រយ៉ាងខ្លាំងពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត (PoE) និងគណៈគ្រប់គ្រងសាលា ផ្តល់ជាមូលដ្ឋានរឹងមាំសម្រាប់ពង្រីកអប់រំបរិយាបន្ន តាមរយៈការសហការនិងការប្តេជ្ញាចិត្តកាន់តែខ្លាំង។
- ការយល់ដឹងអំពីពិការភាពនៅតែមានកម្រិតក្នុងចំណោមបុគ្គលិកសាលាមួយចំនួន និងកង្វះផែនការអភិវឌ្ឍសាលាដែលផ្តោតលើបរិយាបន្ន ធ្វើឱ្យការអនុវត្តមានប្រសិទ្ធភាពត្រូវបានកំណត់។
- កង្វះធនធាន រួមមាន គ្រូបង្រៀនជំនាញជីវិតដែលបានបណ្តុះបណ្តាល អាហារូបករណ៍ ហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពចេញចូល បង្កើតឧបសគ្គដល់សមត្ថភាពសាលាក្នុងការទាក់ទាញ និងចុះឈ្មោះកុមារពិការ។
- ឱកាសបណ្តុះបណ្តាលវិជ្ជាជីវៈយុវជនពិការសតិបញ្ញាមានកម្រិត ដោយខ្វះគ្រូជំនាញ និងកម្មវិធីបណ្តុះបណ្តាលសមស្រប។
- ឪពុកម្តាយខ្លះមានទំនុកចិត្តទាបចំពោះឱកាសការងារនាពេលអនាគតរបស់កូន ដោយគ្រួសារខ្លះជ្រើសរើសឱ្យយុវជននៅផ្ទះជំនួសការចូលរួមបណ្តុះបណ្តាលវិជ្ជាជីវៈ។
- ឧបសគ្គទំនាក់ទំនងនៅកន្លែងការងារ ដោយសារនិយោជកខ្វះបទពិសោធន៍ និងជំនាញក្នុងការគាំទ្របុគ្គលិកពិការសតិបញ្ញា។
- គ្រួសារក្រីក្រ និងគ្រួសារដែលរងផលប៉ះពាល់ពីការធ្វើចំណាកស្រុក បង្កកម្រិតលទ្ធភាពគាំទ្រការអប់រំ និងសេវាពាក់ព័ន្ធ។
- សេវាគាំទ្រផ្សេងៗមិនទាន់ទូលំទូលាយ ជាពិសេសការទទួលបានសេវាព្យាបាលការនិយាយ និងអន្តរាគមន៍ឯកទេសផ្សេងៗ។
- គម្លាតថវិកាបន្តកើតមាន ដោយសារការគាំទ្រពីម្ចាស់ជំនួយមានរយៈពេលខ្លី និងកម្រិតថវិកាមានកំណត់ ប៉ះពាល់ដល់ចីរភាព និងការពង្រីកគំនិតផ្តួចផ្តើមអប់រំរួម។

### យុទ្ធសាស្ត្រសម្រាប់ផែនការបន្ទាប់

- អង្គការសាលារៀនទន្សាយ នឹងបន្តសហការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការអប់រំបរិយាបន្នសម្រាប់កុមារមានពិការភាព ដោយពង្រឹងការយល់ដឹងឪពុកម្តាយ ថ្នាក់ដឹកនាំសាលា និងអាជ្ញាធរមូលដ្ឋាន អំពីការកំណត់អត្តសញ្ញាណពិការភាព តម្រូវការសិក្សាជាក់លាក់ និងសិទ្ធិទទួលបានការអប់រំស្មើភាព។ សកម្មភាពតស៊ូមតិនឹងផ្តោតលើអាជ្ញាធរមូលដ្ឋាន គណៈគ្រប់គ្រងសាលា ការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត ដើម្បីពង្រឹងការប្តេជ្ញាចិត្តចំពោះសិទ្ធិ និងការអភិវឌ្ឍកុមារ។
- ដើម្បីគាំទ្រយុវជនពិការសតិបញ្ញា សាលារៀនទន្សាយ នឹងផ្តល់ការប្រឹក្សាបន្តអំពីជំនាញវិជ្ជាជីវៈ និងឱកាសបណ្តុះបណ្តាលបម្រើការងារ ដើម្បីបង្កើនទំនុកចិត្ត និងការចូលរួម។ ឪពុកម្តាយនឹងត្រូវបានពង្រឹងសមត្ថភាពឱ្យអាចតស៊ូមតិសិទ្ធិកូនៗ កែលម្អជីវភាពរស់នៅ និងគាំទ្រយ៉ាងសកម្មដល់ការអប់រំ និងផ្លូវបន្តបន្ទាប់ទៅកាន់ការងារ។

RGC

- ដើម្បីជានាថីរភាព សាលារៀនទន្សាយ នឹងស្វែងរកភាពជាដៃគូរយៈពេលវែងជាមួយម្ចាស់ជំនួយ ដើម្បីជានាប្រភពថវិកាដែលមានស្ថិរភាព អាចគាំទ្រការពង្រីកសាលារៀន កែលម្អហេដ្ឋារចនាសម្ព័ន្ធបរិយាបន្ន និងលើកកម្ពស់គុណភាពអប់រំសម្រាប់កុមារ និងយុវជនពិការសេតិបញ្ញា និងអូទីស្សឹម។
- សាលារៀនទន្សាយ និងវិទ្យាស្ថានជាតិអប់រំពិសេស នឹងគាំទ្រវិទ្យាល័យអប់រំពិសេស និងគ្រូអប់រំពិសេស តាមរយៈការជួសជុលថ្នាក់រៀន ការរៀបចំបញ្ជីសម្ភារៈបង្រៀន ការកំណត់អត្តសញ្ញាណ ផ្តល់អាហារូបករណ៍ និងការរៀបចំបណ្តុះបណ្តាលគ្រូបន្ថែម។

## 5. ថីរភាព

សូម្បីតែក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា នាយកសាលា គ្រូបង្រៀន និងឪពុកម្តាយ បានសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីដោះស្រាយបញ្ហាប្រឈមថ្មីៗ ដោយធ្វើការចែករំលែកព័ត៌មានអំពីកូវីដ-១៩ ជាប្រចាំ និងជានាបន្តភាពការសិក្សារបស់កុមារ តាមរយៈវិធីសាស្ត្រអនឡាញ។

គ្រូអប់រំពិសេសទាំងអស់របស់អង្គការសាលារៀនទន្សាយ ត្រូវបានទទួលស្គាល់ជាផ្លូវការដោយក្រសួងអប់រំ យុវជន និងកីឡា ជាគ្រូកិច្ចសន្យា និងទទួលបានប្រាក់ឧបត្ថម្ភប្រាក់ខែពីរាជរដ្ឋាភិបាលចំនួន ៨០%។ បន្ថែមពីនេះ សាលារៀនទន្សាយ ត្រូវបានទទួលស្គាល់ជាផ្លូវការដោយរាជរដ្ឋាភិបាលកម្ពុជា រួមមាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង វិទ្យាស្ថានជាតិអប់រំពិសេស ព្រមទាំងអាជ្ញាធរថ្នាក់ក្រោមជាតិ ជាអង្គការមូលដ្ឋានមានវិជ្ជាជីវៈ ដែលមានឯកទេសផ្នែកអប់រំបរិយាបន្ន និងអប់រំពិសេស។

## 6. សកម្មភាពត្រួតពិនិត្យ និងវាយតម្លៃ

សាលារៀនទន្សាយ អនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីជានាការអនុវត្តគម្រោងមានប្រសិទ្ធភាព។ ការចុះត្រួតពិនិត្យជាប្រចាំត្រូវបានអនុវត្តដោយគណៈគ្រប់គ្រងអង្គការ ប្រធានគម្រោង ប្រធានបច្ចេកទេស និងប្រធានកម្មវិធីសហគមន៍ ដោយប្រធានកម្មវិធីសហគមន៍ទទួលខុសត្រូវលើសកម្មភាពប្រចាំថ្ងៃនៅសាលាគោលដៅនីមួយៗ។ ប្រធានកម្មវិធី និងមន្ត្រី M&E អនុវត្តការត្រួតពិនិត្យប្រចាំខែ ព្រមទាំងការតាមដានជាបុគ្គលតាមករណីតាមតម្រូវការ។ នាយិកា និងប្រធានហិរញ្ញវត្ថុ ត្រួតពិនិត្យផែនការ ការគ្រប់គ្រងថវិកា។

នៅកម្រិតសាលា គ្រូបង្រៀនតាមដានវត្តមានសិស្ស និងសកម្មភាពសិក្សាប្រចាំថ្ងៃ ហើយទទួលខុសត្រូវក្នុងការអនុវត្ត និងធ្វើបច្ចុប្បន្នភាពជាប្រចាំនៃផែនការអប់រំផ្ទាល់ខ្លួន។ ឪពុកម្តាយត្រូវបានចូលរួមយ៉ាងសកម្មក្នុងការរៀបចំ IEP និងចូលរួមពិនិត្យវឌ្ឍនភាពកូនរៀងរាល់ ៤ ខែម្តង។ បន្ថែមពីនេះ ក្រុមគ្រប់គ្រង និងបច្ចេកទេសរបស់វិទ្យាស្ថានជាតិអប់រំពិសេស ក៏អនុវត្តការចុះត្រួតពិនិត្យជាប្រចាំ ទៅកាន់វិទ្យាល័យអប់រំពិសេសគោលដៅ ដើម្បីវាយតម្លៃវឌ្ឍនភាព និងផ្តល់ការណែនាំបច្ចេកទេស។

## 7. មេរៀនដែលបានរៀន និងនខាងមុខ

ផ្នែកមួយនៃការអនុវត្តកំណែទម្រង់អភិបាលកិច្ចតាមគោលនយោបាយអភិវឌ្ឍន៍អំណាចថ្នាក់ក្រោមជាតិ ដែលបានចាប់ផ្តើមតាំងពីទសវត្សរ៍ឆ្នាំ ២០០០ រាជរដ្ឋាភិបាលកម្ពុជាបានពង្រឹងមុខងាររដ្ឋបាលនៅកម្រិតស្រុក និងខណ្ឌ ដើម្បីលើកកម្ពស់អភិបាលកិច្ចមូលដ្ឋាន និងការផ្តល់សេវាសាធារណៈឱ្យមានប្រសិទ្ធភាព។ ក្រោមច្បាប់អង្គការឆ្នាំ ២០០៨ រដ្ឋបាលស្រុក/ខណ្ឌ ត្រូវបានផ្តល់ភារកិច្ចពង្រីកបន្ថែម ក្នុងការធ្វើផែនការអភិវឌ្ឍមូលដ្ឋាន ការផ្តល់សេវា និងការគ្រប់គ្រងថវិកា។

ឆ្លើយតបទៅនឹងបរិបទនេះ អង្គការសាលារទន្សាយ បានកែសម្រួលវិធីសាស្ត្រប្រតិបត្តិការរបស់ខ្លួន ដើម្បីសម្របសម្រួលជាមួយកំណែទម្រង់នេះ ដោយពង្រឹងការចូលរួម និងសម្របសម្រួលការងារជាមួយអាជ្ញាធរស្រុក/ខណ្ឌ បន្ថែមលើកិច្ចសហការដែលមានស្រាប់ជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ ការកែសម្រួលនេះជានាបាននូវភាពជាម្ចាស់ការក្នុងមូលដ្ឋាន ការឆ្លើយតបតាមតម្រូវការជាក់ស្តែង និងចីរភាពនៃគំនិតផ្តួចផ្តើមអប់រំរួម។

RSO

## 8. ករណីសិក្សា

### ករណីសិក្សា ១៖ ដំណើរការសិក្សា និងបរិយាបន្នរបស់ សេក កេត សក្ឋណ្ឌិត



សេក កេត សក្ឋណ្ឌិត គឺជាកុមារប្រុសមានអូទីស្សឹម។ គាត់កើតនៅថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០១៤ នៅភូមិវត្តបូរ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប។ បច្ចុប្បន្ន គាត់រស់នៅជាមួយឪពុកម្តាយ គឺលោក សែន សារី និងលោកស្រី ពិន សុធារ៉ា ជាបុគ្គលិកសុខាភិបាលនៅមន្ទីរពេទ្យបង្អែកសៀមរាប។ គាត់មានបងប្អូន ២ នាក់ ហើយគាត់ជាកូនពៅក្នុងគ្រួសារ។

បញ្ហាអូទីស្សឹមរបស់សក្ឋណ្ឌិត ត្រូវបានកំណត់អត្តសញ្ញាណនៅពេលគាត់មានអាយុ ២ ឆ្នាំ ដោយមន្ទីរពេទ្យមេត្តាករុណា (ហៅថា មន្ទីរពេទ្យយាយជី) ដែលមានឯកទេសក្នុងការវាយតម្លៃ និងចាត់ថ្នាក់បញ្ហាសុខភាពផ្លូវចិត្ត នៅខេត្តបាត់ដំបង។ គាត់មានអាកប្បកិរិយាប្រឈមមួយចំនួន ដូចជា ពិបាកប្រាស្រ័យតាមភាសា សមត្ថភាពនិយាយមានកម្រិត ឬពិបាកស្តាប់ ខ្វះការផ្តោតអារម្មណ៍ ចូលចិត្តវាយទ្រូងខ្លួនឯងខ្លាំងៗ ខាំដៃ យំដោយគ្មានមូលហេតុច្បាស់លាស់ និងមានអារម្មណ៍សោកស្តាយជាញឹកញាប់។

នៅឆ្នាំ ២០១៩ សក្ឋណ្ឌិត បានចាប់ផ្តើមចូលរៀនថ្នាក់ទី១ ក្នុងថ្នាក់សមាហរណកម្ម នៅសាលាបឋមសិក្សាខ្នាត ស្ថិតនៅភូមិខ្នាត ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប ដែលមានចម្ងាយប្រមាណ ១៨ គីឡូម៉ែត្រពីផ្ទះ។ ទោះជាយ៉ាងណា ដោយសារការរីករាលដាលជំងឺកូវីដ-១៩ នៅឆ្នាំនោះ គាត់មិនអាចទៅសាលាបានជាប្រចាំ ហើយឪពុកម្តាយបានសម្រេចផ្អាកការសិក្សារបស់គាត់ជាបណ្តោះអាសន្ន។ ក្រោយមក គាត់បានចុះឈ្មោះចូលរៀនឡើងវិញនៅឆ្នាំ ២០២២ និងបន្តសិក្សារហូតដល់បច្ចុប្បន្ន។

ដោយមានការគាំទ្រយ៉ាងជិតស្និទ្ធពីគ្រូអប់រំពិសេស សក្ឋណ្ឌិត បានបង្ហាញការកែប្រែគួរឱ្យកត់សម្គាល់។ សមត្ថភាពទំនាក់ទំនងរបស់គាត់ (ទាំងស្តាប់ និងនិយាយ) បានប្រសើរឡើង អាកប្បកិរិយាកាន់តែប្រសើរ បញ្ឈប់ការវាយខ្លួនឯង មានអារម្មណ៍ល្អជាងមុន និងមានការរីកចម្រើនក្នុងការអាន និងសរសេរភាសាខ្មែរ ទាំងស្រៈ និងព្យញ្ជនៈ អាចអានពាក្យ និងប្រយោគបានរលូន និងមានសមត្ថភាពគណនាផងដែរ។ បច្ចុប្បន្ន គាត់អាចសិក្សារួមក្នុងថ្នាក់ទូទៅ (ថ្នាក់បរិយាបន្ន) ជាមួយសិស្សដទៃទៀត រួមទាំងសិស្សពិការ ផងដែរ ក្រោមការតាមដានយ៉ាងជិតស្និទ្ធពីគ្រូអប់រំពិសេស។



ករណីនេះបង្ហាញថា ថ្នាក់សមាហរណកម្មមានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការលើកកម្ពស់សិទ្ធិស្មើភាពក្នុងការអប់រំ សម្រាប់កុមារពិការសតិបញ្ញា និងអូទីស្សឹម ដោយអនុញ្ញាតឱ្យពួកគេទទួលបានការអប់រំដូចកុមារមិនពិការ។ រាជរដ្ឋាភិបាលគួរពង្រឹងការគាំទ្រដល់ថ្នាក់សមាហរណកម្មដែលមានស្រាប់ទូទាំងប្រទេស និងពង្រីកគំរូនេះឱ្យបានទូលំទូលាយបន្ថែមទៀត។

ឪពុករបស់ សក្ឋណ្ឌិត បានមានប្រសាសន៍ថា៖ *"សូមអរគុណសាលារៀនទន្សាយ និង Aide et Action ដែលបានគាំទ្រដំបូង និងបន្តគាំទ្រឱ្យកូនប្រុសខ្ញុំទទួលបានការអប់រំដូចកុមារដទៃទៀតដែលមានពិការភាព។"*

**ករណីសិក្សា ២៖ ផ្លូវឆ្ពោះទៅកាន់ការរីកចម្រើន និងការរួមបញ្ចូលរបស់ ហូល ចាន់បុរមី**



ហូល ចាន់បុរមី ជាក្មេងស្រីអាយុ ៩ ឆ្នាំ រស់នៅជាមួយឪពុកម្តាយនៅរាជធានីភ្នំពេញ។ ឪពុកម្តាយទាំងពីរជាមន្ត្រីរាជការ។ ចាន់បុរមីកើតមកជាមួយអូទីស្សឹម និងប្រឈមមុខនឹងបញ្ហាខ្លាំងក្នុងការទំនាក់ទំនងសង្គម។ នៅដំណាក់កាលដំបូង នាងមិនដឹងរបៀបលេង បង្ហាញអារម្មណ៍ ចែករំលែកជាមួយមិត្តភក្តិ ឬទំនាក់ទំនងបានប្រសើរឡើយ។ នាងនិយាយបានតែពាក្យខ្លីៗ និងជាញឹកញាប់បង្ហាញអាការៈកង្វល់។

គ្រួសារបានចំណាយថវិកាច្រើន ដើម្បីផ្ញើនាងទៅសាលាឯកជនអប់រំពិសេសជាច្រើនកន្លែង ប៉ុន្តែទោះបីមានការចំណាយខ្ពស់ក៏ដោយ ការរីកចម្រើនរបស់ចាន់បុរមីនៅមានកម្រិត ដែលបង្កើតបន្ទុកហិរញ្ញវត្ថុលើគ្រួសារ។



ចាប់តាំងពីខែមករា ឆ្នាំ ២០២២ ចាន់បុរមីបានចូលរៀននៅសាលារ៉ាប៊ីត ដែលនាងទទួលបានយុទ្ធសាស្ត្របង្រៀនសមស្របតាមតម្រូវការបុគ្គល សម្រាប់សិស្សដែលមានតម្រូវការពិសេសផ្សេងៗ។ តាមរយៈមេរៀនប្រចាំសប្តាហ៍ និងសម្ភារៈសិក្សាផ្អែកលើផែនការអប់រំផ្ទាល់ខ្លួន (IEP) នាងបានបង្ហាញការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយនេះ។ នាងបានឡើងពីកម្រិតទី ១ ទៅកម្រិតទី ៣ អាចនិយាយជាប្រយោគវែងជាងមុន ឆ្លើយសំណួរងាយៗ សរសេរ និងគណនាបានប្រសើរឡើង ហើយមានការយល់ដឹងល្អជាងមុនអំពីគំនិតសង្គម អារម្មណ៍ ការចែករំលែក និងការលេងជាមួយមិត្តភក្តិ។



ម្តាយរបស់នាងបានចែករំលែកថា៖ *"ខ្ញុំបានឃើញការផ្លាស់ប្តូរច្រើនណាស់លើកូនស្រីខ្ញុំ នាងអាចនិយាយពាក្យបានច្រើនជាងមុន ជំនាញសង្គម និងអាកប្បកិរិយាក៏ប្រសើរឡើង ហើយឥឡូវនេះនាងអាចរង់ចាំខ្ញុំតែម្នាក់ឯងបន្ទាប់ពីចប់ម៉ោងសិក្សា។ ខ្ញុំមានក្តីសង្ឃឹមថា នាងអាចចូលរៀនក្នុងថ្នាក់ទូទៅជាមួយសិស្សមិនមានពិការភាព នៅឆ្នាំក្រោយ។"*


ដោយសារការគាំទ្រពី Aide et Action (AEA) និងអង្គការសាលារៀនទន្សាយ សិទ្ធិទទួលបានការអប់រំរបស់ចាន់បុរមីកំពុងត្រូវបានអនុវត្តជាក់ស្តែង និងមានលទ្ធផលមានន័យ។ រឿងរ៉ាវរបស់នាងបង្ហាញពីឥទ្ធិពលបម្លែងជីវិតនៃអប់រំបរិយាបន្ន សម្រាប់កុមារមានពិការភាព នៅកម្ពុជា។

## ឧបសម្ព័ន្ធ៖ រូបថតសមិទ្ធផល

### សកម្មភាពក្នុងថ្នាក់រៀនដែលមានការចូលរួមសកម្មរវាងសិស្ស និងគ្រូបង្រៀន



### កិច្ចប្រជុំជាមួយឪពុកម្តាយ និងការរៀបចំផែនការអប់រំផ្ទាល់ខ្លួន (IEP)



ការផ្តល់សម្ភារៈបង្រៀន





ការផ្តល់អាហារូបករណ៍ជាសម្ភារៈសិក្សា






ការលើកកម្ពស់ឱកាសការងារៈ ទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍សម្រាប់យុវជនពិការសតិបញ្ញា





សាលារៀនទន្សាយ ទទួលដំណើរទស្សនកិច្ចការងារជាមួយ Aide et Action ថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០២៥ ខេត្តសៀមរាប




គ្រូអប់រំពិសេស ពង្រឹងជំនាញក្នុងការព្យាបាលការនិយាយ




ព្រឹត្តិការណ៍ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពីអប់រំបរិយាបន្ន និងការងារសម្រាប់ជនពិការ








សូមអរគុណដល់អ្នកចូលរួម ដៃគូ និងអ្នកគាំទ្រទាំងអស់ ការប្តេជ្ញាចិត្ត និងកិច្ចសហការរបស់អ្នក គឺជាគន្លឹះសំខាន់នៃភាពជោគជ័យ
នៃគំនិតផ្តួចផ្តើមនេះ និងដំណើរឆ្ពោះទៅកាន់អនាគតដែលមានការរួមបញ្ចូលកាន់តែប្រសើរ។

RSO